ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគម្រប់បី

ខ្សែ ៥

ក្រុងភ្នំពេញ
រោងពុម្ពរាជការ គូវែរណើម៉ង្ត
គ្រិ. ឆ្នាំ ១៩៣០
ពុ ស ២៤៧៣

អ្នកទទួលខុសត្រូវ ជុំ-ម៉ៅ

# បញ្ជីរឿង

ទំព័រ

១- ជាឫកថា ក្រុម ពះជំរុះរាជានុភាព អំពីមូលហេតុនៃការព្រះសាសនាស្រុក-សៀម ព្រះមហាពិទូរក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យ ប្រែពីភាសាសៀមមកជាភាសាខ្មែរ (ត) . . . . . ១២៥

២- មិលិន្ទបញ្ហា ព្រះគ្រូវិមលបញ្ញា អ៊ុម ស៊ូរ អាចារ្យនៅព្រះរាជបណ្ណាល័យ កម្ពុជា ប្រែពីបាលីមកជាភាសាខ្មែរ (ត) . . . . .

៣- គតិលោក ឬ ច្បាប់ទូន្មានខ្លួន ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ រៀបរៀង (ត)

( គតិលោក និង មិលិន្ទបញ្ហា មិនបានចុះក្នុងនេះទេ ព្រោះមានបោះសៀវភៅដោយឡែកហើយ ) . . . . . .

៤- រឿងមហាភារតយុទ្ធ ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យ ប្រែពីភាសាសៀមមកជាភាសាខ្មែរ ( ត ) . . . ១៣៧

# មូលហេតុនៃការព្រះសាសនាក្នុងប្រទេសស្យាម

## បាឋកថា របស់ក្រុមព្រះដាំរុងរាជានុភាព

## ព្រះមហាពិទូរក្រសេម

គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែពីភាសាសៀមមកជាភាសាខ្មែរ

( ២ )

---

ប្រវត្តិខាងព្រះសង្ឃនោះកាលគ្រាពុទ្ធសម័យអ្នកដែលចូលបួសជាភិក្ខុសង្ឃ សុទ្ធតែបំណងនឹងបួសនៅរហូតជីវិតទាំងអស់ ដែលបំណងនឹងបួសតែ ១ ពេល ១ គ្រានោះគ្មាន ការដែលកើតមានចាគសិក្ខាបទក្នុងជាន់ពុទ្ធកាល សុទ្ធតែដោយកើតហេតុមែន ៗ សឹងខានពុំបាន យូរ ៗ ទើបមានម្តង វត្តប្រតិបត្តិរបស់ព្រះសង្ឃគ្រាពុទ្ធកាលក៏អនុវត្តទៅតាមពុទ្ធប្រវេណី គឺមិននៅប្រចាំក្នុងទីឯណានីមួយឲ្យជាប់ជានិច្ច រដូវប្រាំងវេលាដើរផ្លូវបានស្រួលក៏បំបែកគ្នាត្រេចទៅប្រដៅពុទ្ធសាសនា តាមស្រុកទេសតូចធំ ឬ បើមិនដូចនោះ ក៏បំបែកគ្នាត្រាច់ទៅរកទីស្ងាត់បំពេញវិបស្សនាញាណ ជម្រះចិត្តរបស់ខ្លួនឲ្យផូរផង់ផុតអំពីកិលេសតណ្ហា លុះដល់រដូវភ្លៀងនឹងដើរផ្លូវមិនស្រួល ទើបរួមគ្នាចូលវស្សា ឈប់សម្រាកនៅក្នុងរោងភូមិស្រុក ទំរាំតែដល់រដូវប្រាំងពំងបុស ក៏ត្រាចទៅជាថ្មី អាស្រ័យប្រវេណីដូចនេះ ទើបមានអ្នកសទ្ធាថ្វាយទីអារាម (ប្រែថាសួន) ដូចយ៉ាងដែលហៅថា ជេតវនារាម និង បុព្វារាម ជាដើម ឲ្យជាទីប្រថាប់ព្រះ

បរមសាស្ថាន ទិងព្រះភិក្ខុសង្ឃសម្រាប់ទឹងបានឈប់សម្រាក នៅក្នុងស្រុក ទេសក្នុងរដូវវស្សា មិនបានជាទីនៅប្រចាំរបស់ព្រះសង្ឃ ដូចយ៉ាងវត្ត ក្នុងប្រទេសយើងនេះទេ ឯវត្តដែលព្រះសង្ឃនៅប្រចាំ កើតឡើងក្នុង ប្រទេសឥណ្ឌាតំណមក ក្នុងជាន់ក្រោយ បើថាតាមបុរាណវត្ថុដែលត្រូវ ទៅប្រទះ គេច្រើនសាងកុដិសង្ឃឡើងក្នុង បរិវេណមហាពុទ្ធចេតិយស្ថាន ដូចយ៉ាងនៅទីព្រះធម្មិកចេតិយ៍ក្នុងតម្បន់មិគទាយវ័ន ដែននគរពារាណសី ដែលជាទីព្រះអង្គទ្រង់សម្តែងបឋមទេសនាជាដើម ឬមិនដូចនោះ ក៏ ធ្វើជាទីសម្រាប់បំពេញសមណធម៌ក្នុងគូហាភ្នំ ដូចយ៉ាងនៅគូហា អែលឡូរ៉ា ក្នុងដែនហៃដារាបាតជាដើម ក្នុងទីដូចពោលមកនេះ ឃើញ មានស្នាមបុសកុដិ ទិងបន្ទប់ទីសំណាក់សង្ឃប្រាកដនៅជាច្រើន ក្នុង ប្រទេសស្យាមក៏មានប្រហែលគ្នា ដូចយ៉ាងនៅទីលានព្រះបឋមចេតិយ៍ ខ្ញុំបានឲ្យជីកពំនូកដី ១ កន្លែងនៅរៀមថ្នល់ខាងព្រះ ត្រង់មុខរោងតម្រួតភូធរ ឥឡូវនេះ ក៏ប្រទះបុសបន្ទប់កុដិព្រះសង្ឃអំពីបុរាណ គូហាសម្រាប់ បំពេញសមណធម៌ក៏មាន ដូចគូហាភ្នំង្ប៍ ក្នុងខេត្តរាជបុរី និងគូហាសួគ៌ គូហាភ្នំអុកជុះ ក្នុងខណ្ឌផ្ទុលុងជាដើម ក្នុងឥណ្ឌាមានទីសម្រាប់ព្រះ សង្ឃនៅរួមគ្នា អំពីបុរាណមួយយ៉ាងទៀត ប្រហែលជាកើតឡើងកាល ជំនាន់ចារព្រះត្រៃបិដកជាក់ជាតួអក្សរហើយ ទំនងជាមហាវិទ្យាល័យ សម្រាប់រៀនធុរៈក្នុងព្រះពុទ្ធសាសនា ដូចយ៉ាងដែលហៅថា សំណាក់ នាលន្ទានៅក្នុងដែននគរបាតលីបុត្រជាដើម សូម្បីដូចនោះក្តី ក៏គង់

សន្និដ្ឋានថា គ្រាន់តែជាទីសង្ឃអាស្រ័យសំណាក់នៅម្តង ៗ មួយគ្រាពល់ កន្លែង ដែលនឹងនៅប្រចាំក្នុងទីកន្លែងនោះតាំងពីបួសឬមកអំពីទីដទៃមក នៅប្រចាំក្នុងទីកន្លែងនោះទាល់រហូតអាយុនោះគ្មាន ព្រះសង្ឃក៏នៅកាន់វត្តប្រតិបត្តិយ៉ាងក្នុងពុទ្ធកាលគឺត្រាចចារិកទៅ ដើម្បីប្រដៅសាសនា ឬស្វែងរកមោក្ខធម៌ មិននៅប្រចាំទីតមកទៀតជាយូរ ៗ

៤. កាលដែលព្រះពុទ្ធសាសនា មកប្រតិស្ឋានក្នុងប្រទេសស្យាមនេះ មានតិកតាងប្រាកដថាមកច្រើនលើក ជាន់ដើមប្រមាណជាក្នុងរវាងពុទ្ធ-សករាជ ៥០០ ឆ្នាំ ពួកអ្នកមជ្ឈិមប្រទេស ( គឺឥណ្ឌាកណ្តាល ) បានអញ្ជើញព្រះពុទ្ធសាសនាលទ្ធិហីនយាន យ៉ាងសម័យព្រះចៅអសោកម-ហារាជមកជាដំបូង ខនេះអាចដឹងបានដោយភាសាដែលចារិកព្រះធម៌យ៉ាងដែលប្រាកដនៅទីព្រះបឋមចេតិយ៍ប្រើភាសាបាលី និងចេតិយវត្ថុយ៉ាងព្រះពុទ្ធរូបនឹងព្រះធម្មចក្រ ដ៏ស្អាតតែជាបែបយ៉ាងក្នុងប្រទេសមគធដ៏ជាទីតាំងនៃលទ្ធិនោះតមក កាលកើតលទ្ធិមហាយានឡើងក្នុងគន្ធារដ្ឋកាលរដ្ឋកាលព្រះចៅ កនិស្ក បានចម្រើនផ្សាយក្នុងឥណ្ឌា កាលពុទ្ធសករាជប្រហែល ៩៤២ ក៏មានពួកអ្នកឥណ្ឌាអញ្ជើញព្រះពុទ្ធសាសនាលទ្ធិមហាយាន មកប្រដៅក្នុងប្រទេសគម្ពាលនេះ មានតិកតាងប្រាកដថា លទ្ធិមហាយានចូលមកប្រទេសស្យាម ២ ផ្លូវ គឺមកអំពីក្រុងកម្ពុជា ១ ផ្លូវ មកអំពីក្រុងស្រីវិជ័យក្នុងកោះសុមាត្រា ផ្សាយមកកាន់ខេត្តនគរស្រីធម្មរាជ ១ ផ្លូវ ខដែលពោលមកនេះ អាចមានចារិកព្រះធម៌ជាភាសា

សំស្រ្កឹតនិងរូបព្រះពោធិសត្វ ដែលកើតឡើងក្នុងលទ្ធិមហាយានប្រាកដ នៅជាតិកតាង អ្នកប្រទេសស្យាមប្រហែលជារាប់អានទាំងពីរលទ្ធិ ឬ រាប់អានលទ្ធិមហាយានជាសំខាន់ ជាងលទ្ធិហីនយាន ដែលផ្សាយមកមុនជាច្រើនឆ្នាំ ខនេះមានតិកតាងនៅពុទ្ធចេតិយ៍ផ្សេងៗ ដែលសាងក្នុងប្រទេសនេះ កាលក្នុងសម័យដែលពោលមក សាងតាមបែបគតិមហាយានជិតទាំងអស់ ព្រះធម៌ក៏ប្រើអក្ខភាសាសំស្រ្កឹត ទាល់តែផ្សាយបរិបូណ៌ទូទៅ លុះដល់សម័យកាលព្រះពុទ្ធសាសនាក្នុងប្រទេសឥណ្ឌាថយថោកខ្សុះដោយផែនដីធ្លាក់ទៅនៅក្នុងអំណាច ពួកកាន់សាសនាដទៃ ពួកទានាប្រទេស ដែលរាប់អានព្រះពុទ្ធសាសនា ក៏ដាច់ការគមនាគម (គឺទៅមកកាន់គ្នា) ដោយកិច្ចសាសនានឹងប្រទេសឥណ្ឌាដែលជាគ្រូដើម មិនតែប៉ុណ្ណោះ ពួកប្រទេសបូព៌ាដ៏តាំងនៅតាមឆ្នេរមាត់ទន្លេ - សមុទ្រ តាំងពីជ្រោយម៉ាឡៃយូភាគខាងក្រោម រហូតដល់កោះសុមាត្រា កោះជ្វា និងនគរចាម ដែលធ្លាប់រាប់អានព្រះពុទ្ធសាសនាមកអំពីមុន ក៏ត្រូវពួកអារ៉ាប់ មកបង្ក្រាបបញ្ចូលឲ្យចូលកាន់លទ្ធិសាសនាឥស្លាម (គឺសាសនាមហាម៉ាត់) ជាច្រើន ប្រទេសដែលកាន់ព្រះពុទ្ធសាសនាផ្លូវនេះ រហូតដល់នគរចាម នគរចិន សល់តែប្រទេសលង្កា ភូមា មន កាន់លទ្ធិហីនយាន ចំណែកឯប្រទេសស្យាមនិងប្រទេសកម្ពុជាកាន់លទ្ធិមហាយាន បានកាន់តាមអំពើចិត្តខ្លួនដោយពួកៗ លុះមកដល់ប្រមាណជា ព.ស. ១៦៩៦ ព្រះចៅបរក្កមពាហុ មហារាជបានគ្រប់គ្រងប្រទេសលង្កា

ទ្រង់ទំនុកបម្រុងព្រះពុទ្ធសាសនា ឲ្យប្រជុំព្រះសង្ឃធ្វើសង្គាយនាព្រះធម៌វិន័យ ក្នុងភាសាបាលីតាមលទ្ធិហីនយាន ហើយចាត់ការគ្រប់គ្រងសង្ឃមណ្ឌលឲ្យសិក្សាធម៌វិន័យ ទាល់តែរុងរឿងឡើង កិត្តិគុណនោះល្បីល្បាញមកដល់ប្រទេសខាងនេះ មានព្រះភិក្ខុសង្ឃខ្មែរ សៀម មន ភូមា នាំគ្នាទៅសិក្សាព្រះសាសនាក្នុងលង្កាទ្វីប ហើយឧបសម្បទាជាថ្មីជាលង្កាវង្ស នាំលទ្ធិហីនយានយ៉ាងលង្កា មកប្រតិស្ឋានក្នុងប្រទេសរបស់ខ្លួន ក្នុងកាលប្រមាណ ព.ស. ១៨០០ អំពីនោះមកប្រទេសស្យាមនិងប្រទេសកម្ពុជា ក៏កាន់ព្រះពុទ្ធសាសនាលទ្ធិហីនយាន យ៉ាងលង្កា ត្រឡប់ប្រើព្រះត្រៃបិដកភាសាបាលី ជាគោលចារឹកព្រះធម្មវិន័យមកហូតដល់សព្វថ្ងៃនេះ ។

៤. បាននិយាយអំពីដំណាលការ ដែលព្រះពុទ្ធសាសនាមក ប្រតិស្ឋានក្នុងប្រទេសស្យាមហើយ អំពីនេះនឹងសម្តែងរឿងសាងវត្តក្នុងប្រទេសស្យាមតទៅ មានសេចក្តីសំខាន់ ១ ១ ដែលអ្នកតែងរឿងអំពីបុរាណ មិនបាននាំពាក្យនឹងយកចិត្តទុកដាក់ គឺ១ដែលមនុស្សនិយាយភាសាខុសគ្នា គម្ពីរដែលតែងអំពីបុរាណច្រើនតែសម្មតិថា មនុស្សសូម្បីផ្សេងជាតិផ្សេងទេសអំពីគ្នា ក៏និយាយចូលចិត្តគ្នាបាន នឹងលើកយកមកពោលជាតួយ៉ាង ដូចយ៉ាងរឿងតំណាលដែលពោលដោយការ ព្រះពុទ្ធសាសនាមកប្រតិស្ឋានក្នុងប្រទេសនេះ ដូចមានប្រាកដក្នុងរឿងសាសនវង្ស ពោលថាកាលគ្រាព្រះបាទស្រីធម្មាសោករាជ និមន្តឲ្យព្រះ-

សង្ឃគ្រាប់ទៅប្រដៅព្រះពុទ្ធសាសនា ក្នុងនានាប្រទេសនោះ ទ្រង់អារាធនាព្រះថេរ ២ អង្គឈ្មោះថាព្រះសោណ ១ អង្គ ព្រះឧត្តរ ១ អង្គ មកប្រដៅសាសនាខាងប្រទេសអំបាលនេះ ព្រះថេរ ២ អង្គនោះកាលមកដល់បានសម្តែងព្រហ្មជាលសូត្រដល់អ្នកប្រទេសនេះៗ ក៏កើតជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ខនេះលមកគិតមើលថា ព្រះថេរទាំង ២ លោកជាអ្នកតាងប្រទេសជាតិឥណ្ឌា ឧបមាដូចយ៉ាងក្លឹងដំបូងទើបចូលមក និយាយភាសាសៀមមិនបាន នឹងមកសម្តែងធម៌ទេសនាដល់អ្នកប្រទេសនេះដោយភាសាអ្វី គិតមើលប៉ុណ្ណោះក៏នឹងឃើញបានថា រឿងដែលពោលក្នុងប្រវត្តិសាសនវង្ស មិនជាខ្លឹមសារ ក៏តែគោលចារឹកទៅមាន ១យ៉ាងទៀតដោយមានបុរាណវត្ថុនៅជាតិកតាង ថាពួកឥណ្ឌាបានមកប្រដៅព្រះពុទ្ធសាសនាក្នុងប្រទេសនេះ ពីក្នុងកាលជិតនឹងសម័យនៃព្រះចៅអសោកមហារាជ ដូចមានប្រាកដនៅព្រះបឋមចេតិយ៍ដូចនេះ ទើបមុខគួរឲ្យសន្និដ្ឋានថា កាលមុនវេលាសម័យនៃព្រះចៅអសោកមហារាជ គង់មានពួកឥណ្ឌាមកតាំងភូមិលំនៅ ឬមកប្រកបការលក់ដូរ នៅក្នុងប្រទេសអំបាលនេះច្រើនមកហើយ ទូតដែលមកប្រដៅព្រះពុទ្ធសាសនា គង់មកប្រដៅពួកឥណ្ឌាផងគ្នាមុន ព្រោះស្តាប់ភាសាគ្នាបាន ពួកឥណ្ឌាអំបាលនោះចេះភាសាសៀម កាលជ្រះថ្លាក្នុងព្រះពុទ្ធសាសនាហើយ ទើបប្រដៅឬធ្វើជាអ្នកប្រែភាសាក្នុងការប្រដៅព្រះពុទ្ធសាសនា ដល់ពួកសៀមក្នុងសម័យនោះតមក ទាល់តែមានពុទ្ធសាសនិកជនក្រាស់ក្រែលឡើងហើយ

ទើបទៅសុំព្រះបរមធាតុ និងគណសង្ឃអំពីឥណ្ឌា ហើយសាងព្រះចេតិយ៍សម្រាប់បញ្ចុះព្រះបរមធាតុ ចំណែកឯអ្នកមានសទ្ធាជ្រះថ្លានឹងបួស ក៏សូមបព្វជាឧបសម្បទនឹងព្រះសង្ឃដែលមកពីឥណ្ឌា ទើបកើតមានវត្ត និងមានសង្ឃមណ្ឌលឡើង ក្នុងប្រទេសស្យាមដោយប្រការដូចនេះ ក្នុងជាន់ដើមព្រះពុទ្ធសាសនាគង់ជាមករុងរឿង តែក្នុងទីជុំនុំធំឬទីក្រុងមុនហើយ ទើបផ្សាយចេញទៅកាន់ទីដទៃដោយលំដាប់ ដោយហេតុនេះវត្តបុរាណដែលប្រាកដនៅ ទើបច្រើនឃើញមានតែក្នុងទីជុំនុំចាស់ និងក្នុងស្រុកដែលជារាជធានីឆ្ងាយចេញទៅមិនសូវឃើញមាន នឹងលើកឧទា-ហរណ៍ដូចយ៉ាងនៅស្រុកនគរបឋម ក្រៅពីព្រះបឋមចេតិយ៍ នៅមានប្រាកដវត្តដែលមានព្រះចេតិយ៍ធំៗ ដែលគេសាងទុកអំពីបុរាណជាច្រើនកន្លែង និយាយតែដែលឃើញបានដោយងាយៗ ក្នុងវេលានេះដូចយ៉ាងវត្តព្រះង៉ាម និងវត្តព្រះប្រធានជាដើម ខ្ញុំធ្លាប់ដែលគិតសង្ស័យថា ព្រះបឋមចេតិយ៍ក៏មានជាទីសក្ការបូជាដំនួសព្រះពុទ្ធអង្គហើយ ហេតុម្ដេចទើបមានអ្នកសាងព្រះចេតិយ៍ អង្គដទៃ ៗ នៅជិត ៗ ក្បែរគ្នា ត្រឹមចម្ងាយប៉ុណ្ណោះកាលបានត្រួតមើលតាមស្រុកដទៃប្រកបគ្នា នឹងមើលតំណាលព្រះពុទ្ធសាសនាក្នុងឥណ្ឌាទើបគិតឃើញថា មូលហេតុដែលសាងវត្តប្រហែលមានជា ២ យ៉ាងតាំងតែអំពីព្រេងនាយមក គឺ ១ យ៉ាងសាងជា ចេតិយ៍ ដែលបញ្ចុះព្រះបរមធាតុ រាប់អានជាគោលចារឹកព្រះពុទ្ធ-សាស ក្នុងទីនោះ ១ យ៉ាងទៀតនោះ វេលាលោកអ្នកទ្រង់គុណធម៌ក្នុង

ព្រះសាសនា ដូចយ៉ាងជាន់គ្រូឧបជ្ឈាយ៍អាចារ្យដែលកប់អានថាជាបុរសដ៏ថ្លៃថ្លាដោយឡែកដល់នូវមរណភាព កាលបូជាសពរួចហើយ បណ្ដាអ្នកដែលកប់អានក៏ជួយគ្នាករជាស្តូបបញ្ចុះអដ្ឋិធាតុតាមប្រវេណីក្នុងឥណ្ឌា តែឧទ្ទិសឲ្យជាផ្ទះព្រះពុទ្ធសាសនាផង ទើបបានកើតមានវត្តដទៃៗ នៅក្នុងទីជិតៗ គ្នា វត្ត ២ យ៉ាងដូចពោលមក ជាដើមនៃចេតនាក្នុងជាន់ក្រោយតមក នឹងសន្មតិហៅតទៅដោយខ្លីថា វត្តពុទ្ធចេតិយ៍ ១ យ៉ាង វត្តអនុសាវរីយ៍ ១ យ៉ាង ៗ

៦- វត្តក្នុងសម័យទ្វារាវតី គឺកាលស្រុកនគរបឋមជារាជធានីរបស់ប្រទេសស្យាមនោះ មើលទៅប្រហែលជាមានតែព្រះស្តូបចេតិយ៍ ជារបស់សំខាន់ ប្អូនកាលមានវិហារសម្រាប់ជាទីប្រជុំសង្ឃនឹងពួកសប្បុរស ១ យ៉ាងទៀតផង តែកេងឧបោសថបុរាណប្រាកដថាគ្មាន ព្រោះសង្ឃនៅមានតិច ការធ្វើសង្ឃកម្មមិនមានទាស់ដោយរឿងខេត្តសីមា កុដិព្រះសង្ឃក៏ប្រហែលជាមានតែនៅទីវត្តពុទ្ធចេតិយ៍ តែព្រះសង្ឃក៏មិនបាននៅប្រចាំក្នុងវត្ត នៅកាន់ប្រវេណីតាមយ៉ាងព្រះពុទ្ធសាវក ត្រាច់ទៅប្រដៅព្រះសាសនាក្នុងទីផ្សេងៗ ជាកិច្ចវត្ត មិននៅប្រចាំកន្លែងឯណានិមួយ ១ នេះនៅមានទំនៀមតមករហូតដល់សព្វថ្ងៃនេះ ក្នុងសំបុត្រដែលព្រះរាជទានទីបង់ព័ទ្ធសីមាក៏មានពាក្យថា ឲ្យជាទីធ្វើសង្ឃកម្មរបស់ព្រះសង្ឃ ដ៏មកអំពីចតុទិស ដូចនេះ លុះដល់មកសម័យអ្នកប្រទេសនេះកាន់លទ្ធិមហាយាន ពិនិត្យមើលចេតិយស្ថាន ដែលសាងខាងប៉ែកបូព៌ា រៀង

មកដល់ពាក់កណ្ដាលប្រទេសស្យាម ដូចយ៉ាងបុរាណវត្ថុដែលប្រាកដ
នៅស្រុកពិម៉ាយ និងស្រុកលពបុរី ស្រីទេព ជាដើម បានបែបយ៉ាងមក
អំពីប្រទេសកម្ពុជា គប្បីយល់បានដូចយ៉ាងធ្វើព្រះប្រាង្គណ៍ជំនួសធ្វើព្រះ
ស្តូបចេតិយ ហើយច្រើនមានរបៀងព័ទ្ធជុំវិញ បុរាណវត្ថុដែលសាង
ស្រុកប៉ែកខាងត្បូង ដូចយ៉ាងនៅស្រុកដៃយាចាស់ ច្រើនធ្វើជារូបមណ្ឌប
ធ្វើរូបព្រះស្តូបចេតិយ៍ជាកំពូលលាស់ ដូចគ្នានឹងព្រះស្តូបចេតិយ៍ ដែល
ពួកមហាយានសាងនៅកោះជ្វា សន្និដ្ឋានថាមកដល់សម័យជាន់នេះ ព្រះ
បរមធាតុកេក្រជាងគេដើម ប្រកបតាំងដោយកើតមានព្រះពុទ្ធរូប និងរូប
ពោធិសត្វសម្រាប់បូជាបរិបូណ៌ឡើងហើយផង ទើបផ្លាស់សេចក្ដីកប់អាន
សាងព្រះស្តូបដែលបញ្ចុះបរមធាតុ ក្លាយទៅធ្វើជាព្រះប្រាង្គណ៍ជាមណ្ឌប
ដែលសម្រាប់ប្រតិស្ឋានព្រះពុទ្ធរូប និងរូបព្រះពោធិសត្វជាគោលសម្រាប់
វត្ត ក្រៅអំពីនោះ ក៏មិនឃើញមានអ្វីប្លែក រោងឧបោសថជាដើមក៏នៅ
មិនទាន់មាន ព្រះសង្ឃខាងមហាយានប្រហែលជារៀវរាយស្ដួចស្ដើង
ណាស់ហើយ យ៉ាងព្រះសង្ឃដែលកាន់លទ្ធិហីនយានមកអំពីដើម បើ
នឹងខុសគ្នាក៏តែខាងវត្តប្រតិបត្តិ គង់ជាមិនជោគជ័យដូចពួកព្រះសង្ឃលទ្ធិ
ហីនយាន ទើបជាហេតុឲ្យមានអ្នកកប់អានច្រើន តែមានតិកតាងប្រា-
កដជាខសំខាន់ ១ យ៉ាងទៀតថា ការដែលកាន់លទ្ធិមហាយានក្នុងប្រ
ទេសនេះផ្សាយឡើងទៅត្រឹមខេត្ត សួគិលោក ជាទីបំផុតខាងលើតែ

ក្នុងមណ្ឌលពាយ័ព្យគ្មានប្រាកដទេក្រោយថា សាសនាលទ្ធិហិនយានធ្លាប់ទៅប្រតិស្ឋានសោះ គង់ជាកាន់លទ្ធិហីនយានយ៉ាងស្រុកមន ស្រុកកូមារហូតមកទាល់តែលទ្ធិលង្កាវង្សផ្សាយចូលមកដល់ ។

(នៅមានតទៅទៀត)

# រឿងមហាភារតយុទ្ធ

ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា

រៀបរៀង

[ត]

---

## ភាគទីប្រាំបួន

## ពួកកុរុចូលផាន់ដែនវិរាដ

ក្នុងរវាងឆ្នាំទីបំផុតនៃការនិរទេសបាណ្ឌវក្សត្រិយ៍ ទុរយោធន៍បានព្យាយាមស៊ើបរកទីសំណាក់ពាក់ពួនលាក់ខ្លួនពួកបាណ្ឌវជានិច្ច បំណែកឯបាណ្ឌវក្សត្រិយ៍ក៏ពឹងពួនលាក់ខ្លួនយ៉ាងសុខុម គ្មានអ្នកណាដឹងដំណឹងឬព្រះហើរហាយសោះដូចប្រាកដហើយខាងដើម គ្រប់ៗ ពួកកងក្រវែលដែលទុរយោធន៍ប្រើទៅឲ្យក្រវែលស៊ើបរកដំណឹងនោះ បានត្រឡប់វិលទៅវិញដោយប្រាសចាកផលដែលបំណងប៉ងមក ទៅថ្លែងការណ៍ថ្វាយទុរយោធន៍ថា ពួកគេបានខ្មីឃ្មាតចេញទៅស៊ើបរកខ្លួនគ្រប់កន្លែងដែលមនុស្សអាស្រ័យនៅ និងក្នុងដែនដងព្រៃរហោឋានមិនបានប្រទះយុធិស្ឋិរ ឬគ្រាន់តែឮដំណឹងសើបសៀបសោះ ទុរយោធន៍ទ្រង់សម្គាល់ថា សត្វសាហាវក្នុងព្រៃគង់ខាំស៊ីបាណ្ឌវក្សត្រិយ៍ទាំងប្រាំទៅហើយ ព្រោះពួកដែលត្រូវនិរទេសចាកនិវេសស្ថានទៅដើរព្រៃ មិនដែលរួចពីខ្លាខាំស៊ី

ទុរយោធន៍រិតតែជឿ ហើយទុកចិត្តជាខ្លាំងឡើងកាលវេលាថា ពួកបាណ្ឌព គ្មានខ្លួនហើយ តាំងនេះព្រោះព្រះហឫទ័យរបស់ទ្រង់ប្រាថ្នាតែឲ្យគួបដិ-បក្សសូន្យទៅអំពីផែនដី ទើបស្រូតទុកដាក់ឲ្យទៅជាដូចនេះដូចនោះជាមុន ឯទោណាចារ្យ គ្មានចិត្តព្យាបាទចំពេញស៊ីសាច់ប្របាច់ឈាមដូចនោះទេ តាំងភីស្មដែលមានព្រះកេសាស្កូវព្រោង គឺដូចគ្នា មិនទ្រង់ជឿសោះថាបាណ្ឌវក្សត្រិយ៍អស់ព្រះជន្ម ព្រះអង្គមានព្រះជន្មាយុកាល ៨០ ឆ្នាំហើយ កិច្ចការតាំងពួងទ្រង់ត្រិះរិះរកហេតុផលឲ្យឃើញជាក់ស្តែងសព្វគ្រប់ ទើបបញ្ចេញវាចាក្នុងរឿងនេះ ក៏ទ្រង់រំឭកថា កុំកាលសន្និដ្ឋានដោយរួសរាន់ហួសទៅ ទ្រង់ទុកព្រះហឫទ័យថា ពួកបាណ្ឌវកាលមានអាវុធគ្រប់ដៃដូចនោះ ក៏ឈ្មោះថាមានពួកច្រើននៅក្នុងខ្លួនសត្វសាហាវយង់ឃ្នង មិនមែនមកប្រឡូងវិទ្ធិពាធាយាយីបានដោយងាយ ៗ ទេ ទ្រង់អាចតស៊ូមនុស្សឬសត្វសាហាវកប់ដោយចំនួនរយពាន់ ងាយខ្ទាន់ធ្ម យ៉ាងអស្ចារ្យជឿថា គង់ជាមិនត្រូវសឹកលបប្រទុស្តរាយបាន ព្រះហឫទ័យភីស្ម ទ្រង់ព្រួយតែទុរយោធន៍វិញ ក្រែងសត្រូវលបរាយបាន ដោយមិនដឹងខ្លួន ព្រោះមកប្រមាថជឿថា សត្វសាហាវនាំបាណ្ឌវក្សត្រិយ៍ស្លាប់បង់ហើយ ក្រិពាចារ្យ ក៏ឃើញត្រូវគ្នានឹងទោណាចារ្យ និងភីស្ម គេមិនបានសម្ងំទុកតែក្នុងចិត្ត កាលទុរយោធន៍ត្រាស់សួររឿងនេះ ក៏ក្រាបទូលមូលគតិតាមត្រង់ ៗ ចំពោះព្រះភក្ត្រថា ៖

ទូលព្រះបង្គំមានសេចក្តីកង្វល់អំពល់ចិត្ត គិតដល់រឿងទិកសភ័យ

នៃព្រះអង្គពន់ពេក មិនសូវជាទៅទឹកដល់ឋាណ្ឌារក្សត្រិយ៍ដែលជឿថា ប្រាសចាកភ័យ មានជីវិតរស់នៅដល់សព្វថ្ងៃនោះទេ ព្រះករុណា ព្រោះពោះបីអាក្រក់ល្អ ក៏ជារឿងរបស់គេ ក៏ឥឡូវឆ្នាំទី ១៣ នៃការនិរទេសទៀបនឹងអស់ហើយ គួរតែព្រះអង្គព្យាយាមផ្សះផ្សារការបាក់បែកគ្នាជាយូរឆ្នាំហើយនេះ ឲ្យជាប់ស្រេចទៅ នឹងបានជាផ្លូវសុខកាយសប្បាយចិត្ត មិនគោងក្ងាក់ផ្អើលតទៅ មិនដូចនោះទឹង..... តែទូលព្រះបង្គំក្រែងព្រះហឫទ័យដែលនឹងក្រាបទូលរឿងពិត ដែលរកនឹងមកផ្តាច់ជីវិតយកទៅក្នុងថ្ងៃឯណាទីមួយក្នុងវេលាក្រោយ ។

តាបុរស(១)ដែលទុរយោធន៍ប្រើទៅស៊ើប បានសេចក្តីល្អិតល្អមកហើយ តែកាលឃើញថា ខ្លួនប្រកែកទឹងគេមិនរួច ទើបក្រាបទូលថា ទូលព្រះបង្គំជាខ្ញុំបានពត៌មានដ៏ល្អ គួរនឹងនាំមកក្រាបទូលឲ្យទ្រង់ជ្រាប យុធិស្ឋិររស់ព្រះជន្មហើយជាប្រាកដ នៅមានពត៌មានល្អជាងនេះទៀត គឺកិច្ចកៈមារ ប្អូនថ្លៃព្រះចៅវិរាដ ក៏ស្លាប់ដោយដៃមនុស្សកំណាចប្រហារបង់ហើយ ទូលព្រះបង្គំត្រេកអរនឹងសង្ឃឹមទុកថា មិនប៉ុន្មានថ្ងៃ ទង់ជ័យនៃពួកកោរពង់ច្រើនរិទ្ធិ នឹងទៅប្រតិស្ឋានលើកំពូលប្រាសាទ ព្រះចៅវិរាដលោសក្នុយយ៉ាងហើយ ។

ទុរយោធន៍ទឹកញញឹមប្រប្រិមក្នុងកមលហឫទ័យ ដូចយ៉ាងកូនក្មេងកំពុងពេញពាល ត្រាស់ឲ្យរៀបកងទ័ពត្រៀមទុកដើម្បីនឹងលើកទៅវាយ

---

១- តាបុរស អ្នកស៊ើប ។

ក្រុងវិពជ ឲ្យសព្វគ្រប់ព្រមទាំងទាហានទាំងគ្រឿងយុទ្ធភ័ណ្ឌ ។

តមកពីបីវេលា កងទ័ពក្រុមានសុសរម័ន អ្នកក្លៀវក្លាវីរឫទ្ធិក្រៃ ក្រៀងហ៊ានជាមេទ័ព បានលើកទ័ពយាត្រាត្រង់ទៅក្រុងវិពជ សុទ្ធតែកងទ័ពដែលបានតាក់តែងយ៉ាងឯកគ្រប់ប្រការ ចាត់យ៉ាងផ្ចិតផ្ចង់តាំងពីផែនទីសម្រាប់ដើរទ័ពចូលទៅវាយនិងការពារខ្លួន រហូតដល់ស្បៀងអាវពលទាហាន ចាត់អ្នករៀបរយដោយថែម ៗ គ្រប់យ៉ាង តាំងពីកាលណាមក កងទ័ពក្រុងដែលលើកចេញពីក្រុងទៅ មិនដែលសម្តែងអាការក្លាវីកកាយ ហើយនឹងបំណងយកជ័យជម្នះដូចនេះ រឿងសេចក្តីស្លាប់កណ្តាលសង្គ្រាមនោះ គេមិនបានគិតយកមកជាអារម្មណ៍ក្នុងចិត្តសោះឡើយ គេបញ្ចូនចិត្តឈោងចំពោះដល់ទីយុទ្ធភូមិឥតមានរួញរា មានតែស្រើបស្រាលសាទរហើកញៀវអឹងអាប់ស្ទើរផ្ទាប់ផែនពសុធា សេចក្តីក្លាហានដូចនេះ លោកវាយតម្លៃថ្លៃជាងសេចក្តីប្រាថ្នានៃអ្នកមានចិត្តលោភគិតតែខាងបាន ។

គ្រានោះព្រះចៅវិពជបានទទួលថ្លែងការណ៍ថា សឹកលើកចូលមកដាន់ដែនវិពជ ទ្រង់មានបញ្ជាឲ្យប្រមូលទាហាន ដើម្បីនឹងលើកទៅតទល់សឹកនឹងកន្លាត់ឲ្យជ្រុះស្រឡះទៅអំពីដែន កុំឲ្យសឹកចូលមកដល់ក្រុងជាមុនទ្រង់ដំណើរកងទ័ពទៅទទួលសឹកនៅទីកណ្តាលវាលធំ កងទ័ពទាំងសងខាងបានមកប្រទះប្រទល់មុខគ្នានៅទីនោះ ឈប់បង្អង់ស្មៀមស្តាប់អាណត្តិសញ្ញា នឹងចូលធ្វើការតយុទ្ធគ្នា កងទ័ពទាំងសងខាងឈរប្រឈមទល់

មុខគ្នា បីដូចជាថា អ្នកបញ្ជាការកងទ័ពទាំងសងខាង កំពុងតាំងគ្រឿងចត ប្រកងទ័ពមុខរបស់ខ្លួនដូចនោះ មួយស្របក់សុសសារ៉េន អ្នកបញ្ជាការកង ទ័ពក្រុងស្រែកប្រកាសថា ចំបាំង ស្នូរសម្លេងព្រួញបាញ់ទៅដល់កងទ័ពម្ខាង លំដាប់នោះកូនសរដូចគ្រាប់ភ្លៀង ក៏ហើរឡើងលើនភាកាស ជួយប្រដូស ប្រប្រាសគ្នាទៅត្រង់ទិសទាំងសងខាងទំគិចគ្នាព្រួសព្រាត១ ឆាប់ ១ ក្នុង កណ្ដាលវេហា កូនសរខ្លះក៏ទៅត្រូវរាងកាយទាហានខាងសឹក កូនសរ ខ្លះ ក៏ធ្លាក់ដល់ដីឥតមានត្រូវការបច្ចាមិត្រ ទាំងពីរពួកក៏សន្ធឹងបាប់ជិត ប្រកិតចូលទៅកលបីដូចលលកសមុទ្រ ប្រុកប្រុកលោលោតចូលទៅប្រហារ គ្នានឹងគ្នាដោយកូនសរ កាន់តែក្រាស់ឡើង ១ ដោយលំដាប់ ព្រួសព្រូវ សត្វអឹកជឹកគឹកកងខ្លាំងឡើង ១ ស្ទើរតែក្រើកអំពើកទាំងផែនពសុធា ចុង ក្រោយមក [illegible] ទាំងសងខាងក៏ចូលប្រឡូកតស៊ូគ្នា ដោយដាវលំពែង អាវុធខ្លីស្រោចដៃ ។

បេតិតទាំងសងខាង មិនតែដេញពលក្លួនបង្គាប់បញ្ជាខ្លួនឲ្យចូលប្រ ឡូកគ្នាប៉ុណ្ណោះ ខ្លួនឯងទាំងពីរបែកបានចំបាំងដ៏ដូចយ៉ាងពលទាហាន កូនសររេមទ័ពទាំងក្រុងបាញ់មកត្រូវព្រះកាយព្រះរាជាភិកដ មានរបួសបន្តិច សូម្បីត្រូវមានរបួសហើយក្ដី ទ្រង់ក៏នៅតែស្ងៀមសេចក្ដីក្លាហានចំបាំងរឿយ ទៅ ដើម្បីនាំសម្រើបចិត្តពលទាហានចំបាំងតទៅ សូម្បីទ្រង់យកព្រះ ហប្ទ័យទុកដាក់ម៉្យាងក្ដី ក្នុងជាន់ដំបូងនេះ នឹងផ្ដឹមមុខទាហានក្រុងមិន បាន ព្រោះកងទ័ពរាជទន់ខាត់ ឬថាមិនស្ទូរប្រសប់ក្នុងយុទ្ធវិធីក៏ថាបាន

សេចក្ដីខនេះធ្វើឲ្យឃើញផលក្នុងខណៈនោះ គឺទាហានក្រុងរិកដបេះតែ ថយក្រោយ រុកទៅមុខទើសទើទៅមិនរួច ថយទៅតាំងមាំហើយក៏របេះ ៗ ថយចូលទៅទៀត ក្នុងមិនយូរប៉ុន្មានក៏ថយផាយទៅតែម្ដង ពាល់តែឃើញថា ទល់ទប់គង់ទ័ពក្រុមិនទឹង ៗ

តមកបន្តិច សុសរម័ន ចាប់ព្រះពជាវិកដបានក្នុងទីចម្បាំងពន្ធនាការ នាំយកទៅទុកក្នុងកងទ័ពក្រុ ទាហានក្រុសប្បាយចិត្តកេអ្វីប្រៀបគ្មាន ស្រែកហៅ ជយោ ៗ ឮសូរសព្ទរំកកងស្មើរផ្គៀងផែនប្រថពី កាលចាប់បានព្រះចៅរិកដទៅហើយ ឈ្មោះថាចប់ ១ ភ្លេងប៉ុណ្ណោះ ការដែលមើលទៅឃើញម្ចាស់ជីវិតរបស់ខ្លួនដំជាកំពូលទ័ព ជាប់អន្ទាក់ទៅក្នុងកណ្ដាប់ដៃសឹកនោះឯង ជាអាណត្តិសញ្ញាមកដាស់តឿនចិត្តអ្នកបន្ទាប់ការគ្រប់ជាន់ ឲ្យកើនពលទាហានដែលកំពុងស្លុត ត្រឡប់ជាមានព្យាយាមរៀងខ្លួន ដើម្បីទឹងប្រាំងយកជ័យជម្នះមកវិញត្រាតែបាន ពួកទាហានរិកដព្យាយាមប្រាំងក្រកនដោយមានក្លាហាន យ៉ាងមិនគិតជីវិតដើម្បីជួយម្ចាស់របស់គេ ឲ្យរួចពីអន្ទាក់នៃអរិកដសត្រូវ ខ្ទលខ្ទាញ់ចូលទៅ មួយលើកហើយមួយលើកទៀត ក៏មិនកើតផលសម្រេចទៅបាន ដោយកម្លាំងសឹកកំពុងឃឹកឃាក់ខ្លាំងណាស់ ការដែលបែកផាយថយមករាល់ដង មុខគួរឲ្យទាហានអាចិត្តតែមិនដូចនោះ ត្រឡប់ជាធ្វើឲ្យទាហានគស់នោះ កើតមានក្លាឡើង ចូលវាយមួយហ៊ុំទៀត កល់បីដូចជាលលកសមុទ្រគ្រាត្រូវពាយុបោកបក់ ការចំបាំងក្នុងលើកនេះឃើញថា

ប្រុះគ្នាហើយឃើញដូចជាញឹកឡើង ៗ គេមិនបានរួមកម្លាំងព្រមគ្នាវាយ ដោយអន្ទើ ៗ ដូចកាលមុន គេពង្រីកថៃវទាហានពយុះហូតទីចម្បាំង ក្នុងទីបំផុតទ័ពក្រុមានអាការធុញក្នុងចិត្តកើតសេចក្តីទើសទាស មិនស្មើ កាតការមានជ័យជម្នះ កើតសេចក្តីកយក្នុងជាន់ដំបូងនោះ ត្រឡប់ជាកេយ រៀអន្តរធានទៅ សឹកខាងក្រុងវិកដឡើងប៉ុនដៃ កាន់តែមានកម្លាំងហ៊ឹក ហ៊ាក់គ្របមកលើខ្លួន លំដាប់នោះ ពល្លក (នេះជានាមប្អូនរបស់ក័យ គ្រាប្អូនខ្លួននៅនៅក្នុងក្រុងវិកដ) បាននៅជួយព្រះបាវិកដឱ្យប្រមូលរួមក បាន ពួកសេនាទាហានរបស់ទ្រង់ នាំគ្នាហ៊ានគឹកកង់វាតទាំងទ័យុទ្ធ ភូមិ ដោយអាងជ័យ ម្តងនេះជាវាព្រះករុវិកដនិងធ្វើការសងសឹកវិញ ទាហានវិកដប្ចូលក់យកាន់តែស្រុះគ្នា ហើយញឹកឡើងព្រិប ៗ ឃើញបាន ផលក្រឡើងដោយលំដាប់ ទាល់តែទ័ពក្រុមទំងបាន ថែកខ្ចាត់ខ្ចាយជាយ ចូលក្រុងហស្តិបុរ ចាប់បានសុសរម័ននទ័ពក្រុបាន តែដើម្បីនឹងសម្តែង មេត្តាចិត្ត ព្រះករវិកដត្រាស់ឱ្យលែងខ្លួនគេ ទៅនគរដើមវិញ ។

ទ័ពក្រុដែលទុរយោធន៍ពាំនៅធ្វើសង្គ្រាមនិងក្រុងវិកដ ដោយ ចិត្តមនោមានក្លាហាន ក៏បរាជ័យដោយប្រការតែប៉ុណ្ណេះម្តង ។

តែសង្គ្រាមដែលទទាបបាញ់ប្រៀបគេគ្រានេះ មុខគួរខ្មាយ សេចក្តីព្រហ៊ើនយង់ឃ្នងរបស់ទុរយោធន៍ឲ្យថយចុះតែមិនដូចនោះ ត្រ-ឡប់ធ្វើជាឱ្យទុរយោធន៍កើតបរិទ្ធណាស់ ឡើងជាងមុនទៅទៀត ប្រ

ញាប់ប្រួមកងទ័ពបានល្មមការហើយ ការលើកក្បួនទ័ពចេញទៅធ្វើសង្គ្រាមនឹងក្រុងវិរាដម្តងទៀតជាគ្រាទី ២ ដោយរួសរាន់ គ្រានេះទ្រង់នាំទ័ពដោយព្រះអង្គឯង ទុរយោធន៍លើកទ័ពទៅគ្រានេះ ចំពោះត្រូវនឹងវេលាដែលព្រះរាជាវិរាដមានរាជកិច្ច តាំងស្តេចចេញចាកព្រះនគរទៅ ដំណឹងទ័ពដឹងដល់សេនាបតីរបស់ព្រះអង្គ គេបានប្រជុំគ្នាជំនួសព្រះនេត្រព្រះសោត ដើម្បីប្រឹក្សារឿងដែលនឹងបាត់ការតស៊ូមហាភ័យដែលកើតឡើងក្នុងបច្ចុប្បន្នបន្ទាន់វេលា ក្នុងកាលដែលព្រះរាជារបស់គេមិននៅ ព្រះរាជបុត្រ វុឌ្ឍតា យានបានទទួលដំណែងជាអ្នកបង្គាប់បញ្ជាកងទ័ព ពេញកិត្តិយស គេបានត្រៀមសេះដំរី និងគ្រឿងយុទ្ធភ័ណ្ឌគ្រប់មុខគ្រប់យ៉ាងដោយរួសរាន់ ទាំងកណ្ឋាពាហនបញ្ចូលជាថ្មីឡើងទៀត បំពេញចំនួនដែលខ្វះខាតក្នុងកាលសង្គ្រាមគ្រាមុនឲ្យជួនការដែលប្រមើលទុក កើតរពោររដើបជ្រួលច្រួលទាំងព្រះរាជអាណាចក្រ សូម្បីតែស្រីក៏មានភាគជំនួយការទ័ពតាមកម្លាំងនិងសេចក្តីអាចរបស់ខ្លួន ត្រង់នេះគួរសរសើរសេចក្តីសាមគ្គីអ្នកស្រុកវិរាដ ។

កាលត្រៀមការព្រមស្រេចហើយ ក៏បានដំណឹងរាជការសឹកមកម្តងទៀតថា សឹកលើកចូលមកដាក់ដែនហើយ កងពាហនក្រុងក៏ម៉្នាលើកទៅធ្វើការរាំងរាទប់អំពីចម្ងាយ កុំឲ្យចូលមកដល់ក្រុង ។

កងទ័ពទាំងពីរបានប្រទះគ្នាម្តងទៀត ភាពនៃការប្រយុទ្ធបានដំណើរ

ទៅយ៉ាងគ្រាមុន ផ្លាស់គ្នាឈ្នះចាញ់ជាធម្មតា សេនាពលហានទាំងពីរពួក មានចំនួនច្រើនអនេកអនន្ត ចូលតយុទ្ធគ្នាខ្វល់ខ្វាញ់ឥតស្រាកស្រាន្ត ប្រហែលហាក់ដូចលលកមហាសមុទ្រ ដេញគ្នាពព្រូនពពាន ប្រទះប្រ-ទាក់គ្នាម្តង ៗ ឮស្នូរគគ្រឹកគគ្រាំ សម្លេងស្រែកបង្អើ សម្លេងផ្គរ ទ្រហ៊ោយំ ពាក្យស្បថ ពាក្យប្រមាថមើលងាយ ពាក្យផ្សុសពេទជេរប្រទេចនានា ទ្រហឹងអឺងកងទាំងផែនយុទ្ធភូមិ ។

ខណៈដែលកំពុងច្បាំង មានរឿងចម្លែកមួយយ៉ាង ដែលជាតិអ្នកចម្បាំងគេមិនធ្លាប់ប្រព្រឹត្ត ព្រះរាជបុត្រព្រះចៅវិរាជអ្នកជាកំពូលទ័ព បញ្ជាការកងទ័ពធំខាងវិរាជ ឃើញពលហានកាប់សម្លាប់គ្នាឈាមប្រោល ក៏ក្រោធជាន់ ខ្ញូចព្រះហឫទ័យទប់ពុំបាន ស្ដេចលបចុះអំពីរថសឹក គេចចេញពីកងទ័ពច្បាំង បែរព្រះភក្ត្រសំដៅបូរី លុះស្ដេចរត់ទៅមួយស្របក់ហើយ នាយសារថីរបស់ទ្រង់ ទើបដឹងថាស្ដេចបាត់ទៅអំពីព្រះរាជរថ ក្នុងជាន់ដំបូងដែលងាកទៅមិនឃើញគេ ស្មានថាព្រះរាជកុមារគង់សុគតដោយថ្វីដៃបច្ចាមិត្រ តែមិនឃើញលោហិតជាប់នៅទីព្រះទីនាំងទ្រង់ដល់ ១ ដំណក់សោះ នាំឲ្យគេឆ្ងល់ហើយសន្និដ្ឋានថា គង់ស្ដេចរត់ទៅជាប្រាកដ ពលហានមួយពួកនេះ បានទទួលបង្គាប់ឲ្យទៅតាមអញ្ជើញស្ដេចមកកាន់រណយុទ្ធភូមិ យូរបន្តិចក៏ឃើញព្រះរាជកុមារកំឡោះ គ្រប់ពលហានឃុំខ្លួនដូចអ្នកទោស ឬដូចឈ្លើយសឹក នាំមកកាន់ទ័ពច្បាំងវិញ ពួក

ពលទាហានរបស់ទ្រង់ពោលសើកសៀតថា មិនគួរឡើយនឹងមកសម្តែង
សេចក្តីកំឡាចក្នុងវេលាកិត្តិយសខ្ពស់មុខ ឬគ្រាទឹកចូលច្រមុះដូចនេះសូម្បី
តែនាយសារថីរបស់ទ្រង់ ក៏អត់គំពេះគំកាយមិនបានជាក្រឡេកឃើញតែ
ឈាម ក៏មុខឡើងស្លេកស្លាំង ព្រលឹងផាយបាត់ដូចស្រ្តី នាយសារថីអ្នក
បររថសឹកនៃព្រះរាជកុមារ រមែងមាននិស្ស័យជាអ្នកចម្បាំង ហើយ
ច្រើនតែជោរ អ្នកចម្បាំងដូចគ្នានឹងអ្នកគង្វៀលលើរថនោះ អ្នកចម្បាំង
កម្លោះតូចពោលគឺនាយសារថីនេះ គេអាក់ខានកាន់អាវុធនៅដៃយូរ
ណាស់ហើយ គេគិតឃើញថា ការដែលគេនឹងចេញមុខធ្វើទៅនោះជា
ការសំខាន់ តែទឹកបារម្ភក្រែងព្រះរាជកុមារមេទ័ពនឹងគេចរត់ទៅទៀត សឹក
នឹងចាប់ខ្លួនបាន ក៏បររថគាត់ទៅជ្រងទីចម្បាំងជាទម្លាងដល់ទៅដើមឈើធំ
ស៊ុំទ្រុមក៏ឡើងទៅលើដើមឈើនោះ យកធ្នូសរនិងបំពង់ព្រួញដ៏ក្រស់
ក្រាំងរបស់គេសឹងលាក់ទុកមកយូរហើយ ៗ ក៏ចុះមករកចៅហ្វាយឡើង
រថបរទៅ តាំងចិត្តនឹងមកជួយតស៊ូរាជសត្រូវ របស់ចៅហ្វាយនាយ
ដោយកូនសរដែលប្រេះចាប់ក្រាំង នោះពាល់តែឃើញខ្មៅឃើញសរ ទើប
ទូលថា ទូលបង្គំនឹងបង្ហាញទ្រង់ឲ្យញ សេះរាទឹងនាំរថទៅឯណា ក៏
តាមតែរ៉ា មើលចុះទាហានគង់ទ័ពធំខាងសឹករលោះទៅច្រើនណាស់
ហើយ ៗ

ទូលដូចនោះហើយ ក៏លើកសរឡើងបាញ់ចេញទៅជាច្រើនព្រួញ ព្រួញមួយទៅធ្លាក់នៅមុខព្រះកក្ត្រកីស្ម កូនសរមួយទៀតទៅធ្លាក់ទៀបជើងទោណអាចារ្យខាងកងទ័ពកុរុ ។

ទោណអាចារ្យភ្ញាក់ខ្លួន លាន់មាត់ថា ច្បាស់ហើយកាលឃើញកូនសរបាញ់មកត្រង់ចំពោះហើយ គេចាប់កូនសរនោះបាន នឹងស្គាល់ខ្លួនអ្នកបាញ់ផង នឹងជាកូនសរដែលធ្លាក់ទៀបជើងគេនោះ អ្នកបាញ់មិនបានតម្រង់ក្បាលគេ អ្នកបាញ់បំណងឲ្យគ្រាន់តែជ្រិះជើងប៉ុណ្ណោះ ងាកទៅរកទុរយោធន៍អ្នកជាស្តេចសឹក ទូលថា ឥឡូវនេះ ទូលបង្គំមានសេចក្តីបារម្ភ ក្នុងរឿងដែលនឹងដណ្តើមយកជ័យ កូនសរនេះមិនមែនកូនសរអ្នកដទៃឆ្ងាយ គឺកូនសរអជ៌ុនជាសិស្សអ្នកមានថ្វីរបស់ទូលបង្គំ សិស្សនេះបើទោះបីឈរនៅក្នុងទីប្រទល់មុខគ្នាម្នាក់ម្នាក់ គួរបាញ់ទៅត្រូវជាប្រាកដ ក៏មានបំណងនឹងបាញ់ឲ្យត្រូវខ្លួនទូលបង្គំ តែនេះគេបង់សម្តែងសេចក្តីគោរពដល់អាចារ្យចាស់របស់គេ ទើបបាញ់សរមកឲ្យគ្រាន់តែឆិតជើង ជាការគំនាប់ជំនួសខ្លួន ។

ទុរយោធន៍ មាយាទ្រង់សំរួលក្នុងកល ក្នុងព្រះហឫទ័យមានសេចក្តីអំណរលន់លើស ដែលបានមកជួបព្រះញាតិ អ្នកត្រូវនិរទេសចាកនិវេសនស្ថាន តាមខសន្យាជាយូរហើយនោះ ទ្រង់អំណរទាំងនេះ

ដោយទ្រង់តម្រិះថា ល្អហើយ ជួបគ្នាគ្រានេះ យើងនឹងបានបន្ថែមទោសនិរទេសគេទៅទៀត ១២ ឆ្នាំ ។

ទុរយោធន៍ ក៏បញ្ចេញសេចក្តីត្រេកអរក្នុងព្រះហឫទ័យឲ្យភីស្មស្តាប់តែខាងភីស្មមិនចង់រវល់ មិនចូលចិត្តនឹងរឿងសាងមហាស្ថានលើនភតល(១) ( គំនិតធ្លុក ) ហើយមិនចង់ចូលទៅនៅក្នុងមហាស្ថានជួបនោះ ដែលអ្នកដទៃនិម្មិតឡើង ។

ខណៈដែលគេកំពុងសន្ទនាជាមួយនឹងទុរយោធន៍នោះ រថសឹកស្តេចសឹកក្រុងវិរាដ ត្រង់ស្ទើរមកក្នុងទ័ពនោះ ព្រួសសូរសន្ធឹកគគ្រឹកហាក់ដូចផ្គរលាន់ ថ្ងៃសរភ្ញាចប្រសាចធ្លាក់ចុះមកក្នុងកណ្តាលកងទ័ពកុរុដូចគ្រាប់ភ្លៀង គ្រាប់ភ្លៀងគឺកូនសរនោះមិនចំពោះតែធ្លាក់ទៅខាងមុខ បានធ្លាក់ព្រាចប្រសាចទៅខាងឆ្វេងខាងស្តាំនៃរថសឹក ដែលបរសំដៅទៅទិសនោះ ៗ រថសឹកដ៏ពន្លឹកនោះ ចូលលុកលុយដេញពលខាងបច្ចាមិត្របែកញែកគ្នាទៅ ជាន់ពលទាហានស្លាប់ត្រៀបត្រាកណ្តាលទ័ពយ៉ាងគ្រានោះនាយសារថីអ្នកមានថ្វីដៃ ទើបទូលស្តេចសឹកថា តោងចំបាំងសឹកយ៉ាងនេះ មើលចុះ ពលទាហានបែកខ្ចាយទៅហើយ ពលទា-ហានរបស់ទ្រង់ ជាជាអ្នកមានជ័យ ។

ព្រះរាជឱរសព្រះចៅវិរាដអ្នកជាកំពូលទ័ពនៃក្រុងវិរាដ ក៏មានជ័យ

---

១- នភតល ផ្ទៃអាកាស ។

ផ្ទះសឹកដោយប្រការដូចនេះ  សំឡេងនិករក្សត្រថ្វាយសព្ទសាធុការគង រំពង  កណ្ដាលពួកសេនាពហាទដែលត្រូវអាវុធមុតជាទម្ងន់  ស្រែកថ្ងូរ រលួងនោះ  ពួកអ្នកស្រុកក៏ហូរហៀរច្រៀតបៀតគ្នាមកពាសពេញផ្លូវថ្នល់ ដើម្បីសម្ដែងសេចក្ដីអំណរក្នុងរឿងមានជ័យ  កាលស្រេចការកម្រាបសឹក ហើយ  អង្គក្សត្រិយ៍សឹកប្រទេសវិពងក៏ស្ដេចឡើងប្រថាប់លើរថសឹក  អ-ធិកទៅដោយចតុរង្គនិកាយត្រឡប់ហ្កានពជណាខ  ទ្រង់សន្ធនារីកពយជា មួយនឹងនាយសារថីអ្នកកក្ដីរបស់ព្រះអង្គ  មកតាមថ្នល់ក្នុងព្រះនគរ ។

(មានតទៅទៀត)